# ព្រះរាជាណាចក្រកម្ពុជា

ក្រុមហ៊ុន គូបេ យៃភែននីស រ៉េស្តូរ៉ង់ **ជាតិ សាសនា ព្រះមហាក្សត្រ**

KOBE JAPANESE RESTAURANT

# កិច្ចព្រមព្រៀង

ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១៥ថ្ងៃ គឺចាប់ពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

ថ្ងៃចន្ទ ទី៥រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវ និងថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោងប្រាំបួនព្រឹក មានកិច្ចប្រជុំមួយនៅ ក្រុមហ៊ុន គូបេ យៃភែននីស រ៉េស្តូរ៉ង់ មានអាសយដ្ឋាន ស្ថិតនៅភូមិ ត្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាបដែលមានចំនួនកម្មករនិយោជិតសរុប ចំនួន ៤៣នាក់ កម្មករនិយោជិតជាស្ត្រីមានចំនួន៣៨នាក់ មាននាយកឈ្មោះ គឹម វិបុល ជនជាតិខ្មែរ ជាតំណាងក្រុមហ៊ុនគូបេយៃភែននីស រ៉េស្តូរ៉ង់ បានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១៥ថ្ងៃ។

ជាកិច្ចចាប់ផ្តើមលោក គឹម វិបុល ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅដល់អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំក្នុងថ្ងៃនេះ បន្ទាប់មកលោកប្រធានអង្គប្រជុំមានមតិសម្របសម្រួលអំពី ករណីខាងលើ និងពន្យល់មូលហេតុដោយសារតែបញ្ហាការផ្ទុះមេរោគឆ្លងជាសាកល កូវីដ-១៩ ធ្វើអោយភ្ញៀវមានការធ្លាក់ចុះយ៉ាងខ្លាំង ដូចនេះក្រុមហ៊ុន គូបេ យៃភែននីស រ៉េស្តូរ៉ង់ និងកម្មករនិយោជិតទាំងអស់ បានព្រមព្រៀងគ្នាដូចខាងក្រោមៈ

១-ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួ១០នាក់រយៈ១៥ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២០ ដល់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។

២-ក្នុងអំឡុងនៃការព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិតនិងទទួលបានប្រាក់ឧបត្ថម្ភ៣០ដុល្លារក្នុង ១៥ថ្ងៃ ។

ខេត្តសៀមរាប,ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០

បានឃើញ និងឯកភាព

តំណាងក្រុមហ៊ុន

តំណាងកម្មករនិយោជិត